ព្រះរាជាណាចក្រកម្ពុជា

HANSOLL
Tailoring to Your Comfort

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងរវាង
# រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនឹងកម្មករ-និយោជិត

យោងតាមស្ថានភាពរោងចក្រនាពេលបច្ចុប្បន្ន មានបញ្ហាខ្វះការបញ្ជាទិញ បានធ្វើឲ្យប៉ះពាល់ពាល់ដល់ខ្សែសង្វាក់ផលិតកម្ម ហេតុដូចនេះ រោងចក្របានទទួលការឯកភាពពីកម្មករ-និយោជិតទាំងអស់ដែលតំណាងដោយសហជីព និងប្រតិភូបុគ្គលិកដូចខាងក្រោម៖

១- កម្មករ-និយោជិតចំនួន ១៧៦៥នាក់ (ស្រីចំនួន ១៦២៤នាក់) ក្នុងចំណោមកម្មករ-និយោជិតសរុបចំនួន ១៨៨២នាក់ ត្រូវព្យួរកិច្ចសន្យាការងារ ចាប់ពីថ្ងៃ ១៩ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២៣។ អំឡុងពេលព្យួរកិច្ចសន្យាការងារនេះ រោងចក្រនឹងផ្តល់អត្ថប្រយោជន៍ស្របតាមសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្មករ-និយោជិតម្នាក់ៗនឹងទទួលបានផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លារអាមេរិក ពីរោងចក្រ និងចំនួន ៤០ដុល្លារអាមេរិកពីរាជរដ្ឋាភិបាល។

២- រោងចក្រនឹងបើកប្រាក់ឈ្នួលលើកទី១ នៃខែមេសា ជូនកម្មករ-និយោជិតនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣។

៣- រោងចក្រនឹងបើកប្រាក់ឈ្នួលលើកទី២ នៃខែមេសា រួមជាមួយនឹងប្រាក់ឧបត្ថម្ភអំឡុងពេលព្យួរការងារចំនួន ៣០ដុល្លារអាមេរិក ជូនកម្មករ-និយោជិតនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣។

៤- កម្មករ-និយោជិតទាំងអស់ត្រូវត្រលប់ចូលធ្វើការងារវិញនៅថ្ងៃសុក្រ ទី០៥ ខែឧសភា ឆ្នាំ២០២៣ ចំពោះកម្មករ-និយោជិតណាដែលមិនត្រលប់មកធ្វើការងារតាមពេលវេលាកំណត់ រោងចក្រនឹងអនុវត្តន៍តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ក៏ដូចជាបទបញ្ញត្តិ និងច្បាប់ស្តីពីការងារ។

**បញ្ជាក់៖** កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចំពោះកម្មករ-និយោជិតទាំងអស់របស់រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនឹងនិយោជកនៃរោងចក្រ ខេមបូ យូនីសូល អិលធីឌី ចាប់ពីពេលចុះហត្ថលេខា នេះតទៅ។

ថ្ងៃចន្ទ ០៦កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ធ្វើនៅកណ្តាល ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣

**ថ្នាក់ដឹកនាំសហជីព និងប្រតិភូបុគ្គលិក** | **អគ្គនាយកក្រុមហ៊ុន**

CAMBO UNISOLL LTD.
KINGDOM OF CAMBODIA

............................ ............................ កាង ម៉ួន សាន់

